របាយការណ៍ប្រចាំខែសីហា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ

## I.ស្ថានភាពមន្ទីរ

### ១-ការងាររដ្ឋបាល បុគ្គលិក

មន្ត្រីរាជការ ចំនួន ៥២ រូប ស្ត្រីចំនួន ០៤ រូប ក្នុងនោះមាន÷

– ប្រធានមន្ទីរ ០១ រូប និង អនុប្រធានមន្ទីរ ០២ រូប

– មន្ត្រីការិយាល័យចំណុះមន្ទីរសរុប÷ ៣២ រូប ស្រី ៤ រូប ក្នុងនោះ មន្ត្រីកម្មសិក្សាថ្មីចំនួន ២ រូប ស្រី ០ រូប និង បុគ្គលិកបណ្តែតចំនួន ២ រូប ស្រី ០១ រូប

– មន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ក្រុង សរុប÷ ១៧ រូប ស្រី ០ រូប ការងារលិខិតស្នាមមាន÷

ㅇ ឱបានទទួលលិខិតចូលតាមបណ្តាក្រសួង អង្គភាពនានា ចំនួន ៣៦ លិខិត

ㅇ បានទទួលលិខិតចូលពីក្រសួងសាម៉ី ចំនួន ១០ លិខិត

ㅇ លិខិតចេញទៅតាមបណ្តាអង្គភាព ស្ថាប័ននានា និងអង្គភាពក្រោមឱវាទចំនួន ៧៣ លិខិត

ㅇ បានធ្វើសំណើសុំពិនិត្យលើរបាយការណ៍ផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារ មន្ត្រីរាជការ ប្រចាំ ខែ កញ្ញា ឆ្នាំ ២០១៥ ដែលមានក្នុងតារាង បៀវត្ស ជូនមន្ទីរមុខងារសាធារណៈខេត្តកំពង់ធំ (សម្រាប់ខែ កញ្ញា ឆ្នាំ ២០១៥ មិនមានការផ្លាស់ ប្តូរ ស្ថានភាពរដ្ឋបាលទេ)

ㅇ បានធ្វើរបាយការណ៍វឌ្ឍនភាពសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារ សម្រាប់ខែសីហា ឆ្នាំ ២០១៥ ដែលមានក្នុងតារាងទូទាត់ បៀវត្ស មានដូចខាងក្រោម ÷

| ស្ថាប័ន/អង្គភាព | ចំនួនមន្ត្រីក្នុងតារាងបៀវត្ស | ចំនួនមន្ត្រីមានគណនីធនាគារ | ចំនួនមន្ត្រីមានបើកបៀវត្សតាមធនាគារ | ចំនួនមន្ត្រីគ្មានគណនីធនាគារ | ចំនួនមន្ត្រីជាក់ស្តែង |
|---|---|---|---|---|---|
| មន្ទីរអ ជ ប ខេត្តកំពង់ធំ | ៥២ | អេស៊ីលីដា= ៥២ ន | ៥២ | ០០ | ៥២ |

### ២-ការងារគណនេយ្យ និង ហិរញ្ញវត្ថុ

| ជំពូក | បរិយាយ | ស្ថានភាពឥណ ទាន គិតជារៀល | បណ្តាខែមុន | ចំណាយក្នុងខែ 08 | ចំណាយ បូក យោង | សមតុល្យ |
|---|---|---|---|---|---|---|
| ៦០ | ការទិញ | 154,700,000 | 5,119,050 | 5,503,500 | 10,622,550 | 144,077,450 |
| ៦១ | សេវាខាងក្រៅ | 426,600,000 | 70,411,350 | 20,105,800 | 90,517,150 | 336,082,850 |
| ៦៣ | ពន្ធ និងអាករ | 3,000,000 | 0 | 0 | 0 | 3,000,000 |
| ៦៤ | បន្ទុកបុគ្គលិក | 414,680,000 | 204,619,410 | 342,000 | 204,961,410 | 209,718,590 |
| សរុបរួម | | 998,980,000 | 280,149,810 | 25,951,300 | 306,101,110 | 692,878,890 |

### ៣-ការងារផែនការ និងស្ថិតិ

បូកសរុបរបាយការណ៍វឌ្ឍនភាពប្រចាំខែសីហា ឆ្នាំ ២០១៥

**៤-ការងាររដ្ឋបាលកិច្ច និងសវនកម្ម** (គ្មានសកម្មភាព)

**៥-ការងារទំនាក់ទំនងសាធារណៈ និងកិច្ចប្រជុំផ្សេងៗ**

- លោក មុំ ចែម ប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមនៅថ្នាក់ខេត្តបានចំនួន ១១ លើក
- លោក តាន់ វាសនា អនុប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមថ្នាក់ខេត្តបាន ០៥ លើក
- លោក សេង ជាសុខ អនុប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមថ្នាក់ខេត្តបាន ០៧ លើក
- ថ្ងៃទី ២០-០៨-១៥ មន្ទីរបានរៀបចំប្រជុំប្រចាំខែ ស្តីពីការងារបូកសរុបរបាយការណ៍ប្រចាំខែកក្កដា និង ផ្សព្វផ្សាយពី ករណី ឯកឧត្តម ហុង សុខហួរ សមាជិកព្រឹទ្ធសភា ក្រោមអធិបតីភាពលោកប្រធានមន្ទីរ មានការចូលរួមពីលោកអនុប្រធានមន្ទីរ និងប្រធាន អនុប្រធានការិយាល័យ និងមន្ត្រីរាជការទាំងអស់ក្នុងមន្ទីរ

II. **សកម្មភាពតាមវិស័យ**

**១-ការងារផ្លូវជនបទ** (ថវិកាកម្មវិធី)

- បានធ្វើបច្ចុប្បន្នភាពខ្សែផ្លូវស្ថិតក្នុងស្រុកប្រាសាទសំបូរ ប្រាសាទបល្ល័ង្គ បានចំនួន ៦ ខ្សែ ប្រវែងសរុប ៨០,៩០ គ.ម
- បានលើកសំណើគម្រោងជួសជួលលក្ខណៈខួប សម្រាប់គម្រោងថវិកាខេត្ត ឆ្នាំ ២០១៥

**២-ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ** (ថវិកាកម្មវិធី)

បានអនុវត្ត ការងារ សាងសង់អណ្តូងថ្មី និងជួសជុលអណ្តូង ចំនួន ៧៤ កន្លែង ក្នុងខេត្ត ប្រចាំឆ្នាំ ២០១៥ ក្នុងនោះ÷

- ការងារសាងសង់អណ្តូងថ្មី ស្នប់អាហ្វ្រីដេវ បានចំនួន ០៦ អណ្តូង នៅភូមិរស្មីរំដោះ ឃុំសូយោង ស្រុកបារាយណ៍ សម្រេចបាន ១០០%
- ការងារជួសជុលស្នប់អាហ្វ្រីដេវ បានចំនួន ០១ អណ្តូងលើ ០៤ អណ្តូង នៅភូមិ បន្ទាយចាស់ ឃុំត្នោតជុំ ស្រុកបារាយណ៍បាន ៦០%
- ការងារជួសជុលអណ្តូងលូចម្រុះ បានចំនួន ០៤អណ្តូង លើ ០៥អណ្តូង នៅភូមិបន្ទាយចាស់ ឃុំត្នោតជុំ ស្រុកបារាយណ៍ បាន ៦០%
- ការងារជួសជុលអណ្តូងលូចម្រុះ បានចំនួន ០៣ អណ្តូង នៅភូមិត្នោតជុំ ១ ឃុំត្នោតជុំ ស្រុកបារាយណ៍ សម្រេចបាន ១០០%
- ការងារជួសជុលអណ្តូងលូចម្រុះ បានចំនួន ០២ អណ្តូង នៅភូមិត្នោតជុំ ២ ឃុំត្នោតជុំ ស្រុកបារាយណ៍ សម្រេចបាន ១០០%
- ការងារជួសជុលអណ្តូងលូចម្រុះ បានចំនួន ០២ អណ្តូង នៅភូមិត្នោតជុំ ៣ ឃុំត្នោតជុំ ស្រុកបារាយណ៍សម្រេចបាន ១០០%

មន្ទីរបានចុះប្រមូលទិន្នន័យ និងត្រួតពិនិត្យស្ថានភាពអណ្តូងនៅភូមិថ្មី ឃុំត្នោតជុំ ស្រុកបារាយណ៍លទ្ធផលដែលបានអណ្តូងសរុប ៦៤ អណ្តូង (អាហ្វ្រីដេវ ១១ ជីកអត់លូ ២ និងអណ្តូងលូចំនួន ៥១)។

**៣-ការងារសុខភាពអនាម័យជនបទ**

- ថ្ងៃទី ២៩-០៧-១៥ បានចូលរួមប្រជុំគណៈកម្មាធិការហិរញ្ញប្បទានថ្នាក់ខេត្ត ដើម្បីបូកសរុបរបាយការណ៍ការងារប្រចាំត្រីមាសទី ២ ឆ្នាំ ២០១៥ អ្នកចូលរួមមន្ទីរពាក់ព័ន្ធ និងអង្គការជុំវិញខេត្ត សរុបចំនួន ២០ នាក់ ក្នុងនោះខ្លឹមសារអង្គប្រជុំ÷ ១-ពិនិត្យលើរបាយការណ៍របស់គណៈកម្មាធិការហិរញ្ញប្បទាន ២-ការសុំកែសម្រួលសេវារបស់សុខាភិបាល ៣-ការបង្កើតគណៈកម្មាធិការហិរញ្ញប្បទានថ្នាក់ស្រុក
- ថ្ងៃទី ៣០-០៧-១៥ បានចូលរួមប្រជុំការងារបច្ចេកទេសសុខាភិបាលប្រចាំខែកក្កដា ស្តីពីលទ្ធផលបូកសរុបរយៈពេល ៦ ខែ ឆ្នាំ ២០១៥ របស់មន្ទីរសុខាភិបាលខេត្ត និងមានការបង្ហាញពីសកម្មភាពអនុវត្តរបស់អង្គការ MARIESTOPE អ្នកចូលរួមមន្ទីរពាក់ព័ន្ធ និងអង្គការជុំវិញខេត្ត សរុប ២៦ នាក់
- ចុះប្រមូលព័ត៌មានទិន្នន័យបង្គន់អនាម័យ បានចំនួន ០៤ ភូមិ គឺភូមិក្រសាំងជ្រុំជើងក្រសាំងជ្រុំត្បូង ដូនល្អ និងភូមិអូររំចេក ក្នុងឃុំសំព្រោជ ស្រុកស្ទោង លទ្ធផលបានចំនួន ៤៣៧ បង្គន់
- ថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៥ ដោយមានការសហការ និងជួយឧបត្ថម្ភគាំទ្រថវិកាពីអង្គការទស្សនៈពិភពលោកប្រចាំតំបន់អភិវឌ្ឍន៍ ស្រុកស្ទោង មន្ទីរ បានធ្វើការរៀបចំពិធីអបអរសាទរប្រកាសលទ្ធផល "សហគមន៍បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល "នៅភូមិក្រសាំងជ្រុំជើង ឃុំសំព្រោជ ស្រុកស្ទោង ក្រោមអធិបតីភាព **ឯកឧត្តម ហួន វ៉ាន់និត** អភិបាលរងខេត្តកំពង់ធំ ដោយមានការអញ្ជើញចូលរួមជាអធិបតី លោក **សេង ជាសុខ** អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត លោក **ឆួយ កុសល** អភិបាលរង ស្រុក ស្ទោង លោក **ស៊ុយ គឹមសៀក** តំណាងអង្គការទស្សនៈពិភពលោក ជាប្រធានតំបន់អភិវឌ្ឍន៍ស្ទោង ២ និងមានការចូលរួមពីក្រុមប្រឹក្សាឃុំ សមាជិកឃុំ មេភូមិ ជនបង្គោលអនាម័យភូមិ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋសរុបប្រមាណ ៣០០ នាក់ ស្រី ២១០ នាក់

**៤-ការងារអភិវឌ្ឍន៍សហគមន៍** (ថវិកាកម្មវិធី) (គ្មានសកម្មភាព)

**៥-ការងារបណ្តុះបណ្តាល និងស្រាវជ្រាវ** (សកម្មភាពអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងប្រទេស)

| ល.រ | ប្រភេទវគ្គ | | | | ឈ្មោះមន្ត្រីចូលរួម | តួនាទី | ខ្លឹមសារ | រយៈពេល | ចំនួនថ្ងៃ | ទីកន្លែង | អង្គភាពរៀបចំ |
|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ទ | ស.រ | | | | | | | |
| 1 | ប | | | | 1-លោក ប្លង់ សាឡន | ប្រធានការិ-មន្ទីរ | ស្តីពីការពង្រឹងតួនាទីមន្ត្រីជួរមុខរបស់អគ្គលេខាធិការនៃ គ ជ គ ជ | 5-6/08/15 | 2 | កំពង់ធំ | ក្រសួងមហាផ្ទៃ |
| 2 | | ស | | | 1-លោក សេង ជាសុខ<br>2-លោក លី សុផល<br>3-កញ្ញា ពេជ្រ រដ្ឋា | អនុប្រធានមន្ទីរ<br>អនុប្រធានការិ-មន្ទីរ<br>និង មន្ត្រី | ស្តីពី ការធ្វើបច្ចុប្បន្នភាពគោលការណ៍គ្រប់គ្រងធនធានមនុស្ស និងនិតិវិធីឥណទានជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ | 11-12/08/15 | 2 | កំពង់ចាម | MRD |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 3 | | ស | | | 1-លោក ប្លង់ សាឡន | ប្រធានការិ-មន្ទីរ | ស្តីពី ការផ្សព្វផ្សាយផែនការសកម្មភាព | 11/08/15 | 1 | កំពង់ធំ | ក្រសួងកិច្ចការនារី |

**៦-ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ** (គ្មានសកម្មភាព)

**៧-ការងារជនជាតិដើមភាគតិច** (គ្មានសកម្មភាព)

**៨-ការងារ** Gender÷ (គ្មានសកម្មភាព)

**៩-អង្គការក្នុង និង ក្រៅរដ្ឋាភិបាលក្រោមកិច្ចសហការជាមួយមន្ទីរ**

៩.១.អង្គការ iDE ÷ បានលក់ចែកបង្គន់អនាម័យជូនប្រជាពលរដ្ឋបានចំនួន ៥៣៣ ឈុត

៩.២.អង្គការស្អាតកម្ពុជា ÷ស្រុក បារាយណ៍ និងស្រុកសន្ទុក (គ្មានរបាយការណ៍)

៩.៣.អង្គការ CARITAS ÷ (គ្មានរបាយការណ៍)

៩.៤.អង្គការ សកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD) (គ្មានរបាយការណ៍)

៩.៥. CWS (គ្មានរបាយការណ៍)

៩.៦.អង្គការ Moslim Aid (គ្មានរបាយការណ៍)

៩.៧. WVC ÷ បានសហការជាមួយមន្ត្រីមន្ទីរ ទទួលបានលទ្ធផលដូចខាងក្រោម÷

- លោកអនុប្រធានមន្ទីរ និងមន្ត្រីជំនាញការិយាល័យសុខភាពចំនួន ០១ រូប បានធ្វើការសហការការងារ CLTS ជាមួយអង្គការដៃគូរអភិវឌ្ឍន៍ (WVC) ស្រុក ស្ទោង មានរយៈពេល ២ ថ្ងៃ គឺនៅថ្ងៃទី ២៧-២៨ ខែកក្កដា ឆ្នាំ ២០១៥ ដើម្បីធ្វើការវាយតម្លៃភូមិក្នុងជំហានទី ២ ស្តីពីការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល នៅភូមិក្រសាំងជ្រុំជើង ឃុំសំព្រោជ ស្រុកស្ទោង សមាសភាពអ្នកចូលរួមវាយតម្លៃ សរុបចំនួន ១៨ នាក់ និងអ្នកសម្របសម្រួលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០២នាក់ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ចំនួន ០១ នាក់ និងតំណាងអង្គការទស្សនៈពិភពលោកចំនួន ០១ នាក់
- ថ្ងៃទី ១៣-១៤ ខែសីហា ឆ្នាំ ២០១៥ លោកអនុប្រធានមន្ទីរ និងមន្ត្រីជំនាញការិ-សុខភាពជនបទ ០១ រូប និងមន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ០១ រូប បានចូលរួមប្រជុំ បូកសរុបលទ្ធផលការងារថ្នាក់ឃុំត្រីមាសទី ២ និងការធ្វើផែនការបន្ត របស់ឃុំសំព្រោជ មានរយៈពេល ២ ថ្ងៃ នៅការិយាល័យអង្គការទស្សនៈពិភពលោក ស្រុកស្ទោង មានអ្នកចូលរួមសរុបចំនួន ៣៦ នាក់ ស្រី ១៣នាក់
- ថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៥ លោកអនុប្រធានមន្ទីរ និងមន្ត្រីជំនាញការិយាល័យសុខភាពជនបទ ០១ រូប និងមន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ០១ រូប ចូលរួមអមអរសាទរពិធីប្រកាសលទ្ធផលសហគមន៍បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលនៅភូមិក្រសាំងជ្រុំជើង ឃុំសំព្រោជ ស្រុកស្ទោង
- បានចុះសម្របសម្រួលវគ្គ ស្តីពីការរៀបចំធ្វើទិវង់នៃលិខិតបទដ្ឋាន និងពង្រឹងសមត្ថភាពដល់គណៈកម្មការទ្រទ្រង់សាលា និងសហគមន៍ចេះរបៀបសរសេរសំណើរបាយការណ៍ កំណត់ហេតុដោយ

មាន អ្នកចូលរួមសរុបចំនួន ៣៥ នាក់ ស្រីចំនួន ៨ នាក់ នៅស្រុកស្ទោង

៩.៨.អង្គការ ពន្លឺអភិវឌ្ឍន៍ (APA) (គ្មានរបាយការណ៍)

៩.៩.អង្គការ ស្រែខ្មែរ ÷(គ្មានរបាយការណ៍)

៩.១០.អង្គការ ADRA (គ្មានរបាយការណ៍)

៩.១១.អង្គការ HOM (គ្មានរបាយការណ៍)

៩.១២.អង្គការ ESSD (គ្មានរបាយការណ៍)

៩.១៣.អង្គការ ទឹកស្អាត ១០០១ (គ្មានរបាយការណ៍)

**១០-កម្មវិធី និងគម្រោង**

**១០.១-គម្រោងផ្គត់ផ្គង់ទឹកនិងអនាម័យជនបទទី២**(RWSSSP-2)(មន្ត្រីចំនួន០៣នាក់)

ការងារសាងសង់បង្គន់អនាម័យនៅឃុំមានរិទ្ធ ស្រុកសណ្តាន់ សហគមន៍មិនទាន់សាងសង់មានចំនួន ៣៩២ បង្គន់។ ចំណែក ឃុំ មានជ័យ នៅសល់បង្គន់ចំនួន ៣៤ បង្គន់ ដែលមិនទាន់សាងសង់ ដោយពួកគាត់ធ្វើចំណាកស្រុក។

**១០.២-គម្រោងផ្លូវក្រាលកៅស៊ូ** (RRIP-2) (មន្ត្រីចំនួន ០៤ នាក់) (គ្មានសកម្មភាព)

**១០.៣-កម្មវិធី** WFP (ផ្លូវជីស)(មន្ត្រីចំនួន ០៤ នាក់)

ការងារស្បៀងសម្រាប់ទ្រព្យធនសហគមន៍បញ្ចប់ ១០០% ដែលមានជាអាទិ៍÷

– លំសង់ថ្មី÷ចំនួន ១៦ គម្រោង ប្រវែង ១៤,៣៥ គ.ម អស់ស្បៀង ២៧៣,២ តោន

– ផ្លូវលំជួសជុល÷ចំនួន ៥ គម្រោង ប្រវែង៤,៥៩ គ.ម អស់ស្បៀង ៥៧,៩៥ តោន

– ទំនប់សង់ថ្មី÷ ចំនួន៨គម្រោង ប្រវែង ៨,៥២ គ.ម អស់ស្បៀង ១២៤,៤៥ តោន

– ប្រឡាយសង់ថ្មី÷ ចំនួន ១ គម្រោង ប្រវែង ០,៦៧៣ គ.ម អស់ស្បៀង ១១,៦៥ តោន

– អ្នកចូលរួមជាមួយគម្រោងផ្ទាល់ ២.៦៦៩ គ្រួសារស្មើនឹង ៦.០១១ នាក់ ស្រី ២.៨៩០ នាក់

**១០.៤-គម្រោងអភិវឌ្ឍន៍ជនបទវាលទំនាបបឹងទន្លេសាប** (មន្ត្រីចំនួន០៥នាក់)(គ្មានសកម្មភាព)

**១០.៥-គម្រោង** ( RIP-III)(មន្ត្រីចំនួន ០៤ នាក់)(ចប់សកម្មភាព)

**១០.៦-កម្មវិធី ទឹកស្អាត និង អនាម័យ** ( UNICEF) (មន្ត្រីចំនួន ៤ នាក់)

នៅឃុំទីពោធ ស្រុក សន្ទុក ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ មន្ត្រីមន្ទីរ ចំនួន ០៣ រូប បានចុះជួបប្រជុំ ស្តីពីការផ្តល់ព័ត៌មានអំពីផែនការអនុវត្តកម្មវិធី HWTs ក្នុង ១៤ ភូមិ មានការចូលរួមពីអាជ្ញាធរភូមិ ឃុំ និងប្រជាពលរដ្ឋ សរុបចំនួន ៣៤ រូប ស្រី ០១ រូប

– បានចងក្រងជាក្រុម បន្សុទ្ធនិងស្តុកទឹកឱ្យមានសុវត្ថិភាពតាមគ្រួសារ ទៅតាមចំនួនខ្នងផ្ទះក្នុងភូមិនីមួយៗសរុប ១៤ ភូមិមានចំនួន ១២៦ ក្រុម

– ចុះរៀបចំចងក្រងក្រុម HWTs និង បានបើកវគ្គបណ្តុះបណ្តាលដល់ ក្រុម HWTs ១២៦ ក្រុម

នៅថ្ងៃទី ០១-១៦ ខែ កក្កដា ឆ្នាំ ២០១៥ មន្ត្រីការិ-អភិវឌ្ឍន៍ស្រុក ចំនួន ០១ រូប និងសហគមន៍ចំនួន ១៤ រូប បានចុះពិនិត្យ និងរៀបចំចងក្រងក្រុម ( HWTs) តាមភូមិទាំង ១៤ ភូមិ ក្នុងឃុំ ទីពោធ ដែលមានប្រធាន

ក្រុម ១២៦ ក្រុមក្នុងនោះមាន÷

- ភូមិទីពោមាន ១១ ក្រុម ២-ភូមិថ្មី មាន ០៨ ក្រុម ៣-ភូមិក្បាលបី មាន ០៥ ក្រុម ៤-ភូមិ ត្រពាំងត្រុ មាន ០៥ ក្រុម ៥-ភូមិផ្លុង ២១ មានក្រុម ៦-ភូមិសំរោងមាន ០៤ ក្រុម ៧-ភូមិឈូករជួលមាន ១៣ ក្រុម ៨-ភូមិជាំថ្នាញមាន ០៨ក្រុម ៩-ភូមិតាព្រាច មាន ០៩ ក្រុម ១០-ភូមិសែនអភិវឌ្ឍន៍ ១ មាន ០៨ក្រុម ១១-ភូមិសែនអភិវឌ្ឍន៍ ២ មាន ០៧ ក្រុម ១២-ភូមិ ស្រែស្រម៉មាន ០៩ ក្រុម ១៣-ភូមិ អូរធំមាន ០៦ ក្រុម ១៤-ភូមិ និមិត្តមាន ១២ ក្រុម
- ថ្ងៃទី ០១ ដល់ ៣១ ខែ កក្កដា ឆ្នាំ ២០១៥ មន្ទីរ ក្រោមការជួយគាំទ្រថវិកាពីអង្គការយូនីសេហ្វ បានសហការជាមួយ មន្ទីរព័ត៌មានខេត្តកំពង់ធំ ដើម្បីរៀបចំកម្មវិធីសំណួរ ចម្លើយ តាមវិទ្យុស្តីពីការលើកកម្ពស់អនាម័យជនបទ សម្រេចបានលទ្ធផលដូចខាងក្រោម÷
- ចំនួនអ្នកចូលរួមសរុប មាន ១២០ នាក់ ភាគច្រើនអ្នកក្នុងខេត្ត មានស្រុកស្ទោង ប្រាសាទសំបូរ សណ្តាន់ កំពង់ស្វាយ បារាយណ៍ សន្ទុក និងក្រុងស្ទឹងសែន និងមកពីក្រៅខេត្ត មួយចំនួន ។
- ក្នុងអ្នកចូលរួមសរុប ១២០ នាក់ មានកម្រិតនៃការយល់ដឹង÷ ល្អស្មើនឹង ៧៥ នាក់ បង្គួរស្មើនឹង ៣៥ នាក់ និងមធ្យម ស្មើនឹង ១០ នាក់
- អ្នកចូលរួមបានអនុវត្តអនាម័យល្អ ដូចជា÷ប្រើប្រាស់បង្គន់អនាម័យ ស្មើនឹង ៨៦ គ្រួសារ លាងដៃនឹងសាប៊ូ ស្មើនឹង ៥០ គ្រួសារ និងមានការហូបទឹកមានសុវត្ថិភាព ៧០ គ្រួសារ

នៅក្នុង ខែ កក្កដាឆ្នាំ ២០១៥ មន្ទីរបានសហការជាមួយមន្ទីរព័ត៌មាន ខេត្តកំពង់ធំ ដើម្បីរៀបចំកម្មវិធីការពិភាក្សា វេទិកាតុមូលស្តីពីការលើកកម្ពស់អនាម័យនៅជនបទ ដោយមានការចូលរួមពី មេឃុំ គ.ក.ន.ក មេភូមិ និងមន្ត្រី មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត មន្ទីរអប់រំ យុវជន និង កីឡាខេត្ត មន្ទីរសុខាភិបាលខេត្ត លើប្រធានបទដូចខាងក្រោម÷

- ថ្ងៃទី ០៤ -១១ /០៧/១៤ ពិភាក្សាលើប្រធានបទស្តីពី ការលើកម្ពស់ទឹកស្អាត និងអនាម័យជនបទ តាមាសាលារៀន និងសហគមន៍ ។ ប្រធានបទ ស្តីពី ការលើកម្ពស់វិស័យទឹកស្អាតនៅតាមជនបទ (ការបន្សុទ្ធ ស្តុកទឹកឲ្យមានសុវត្ថិភាពតាមគ្រួសារ)

**១០.៧-កម្មវិធីកំចាត់មីនខេត្ត** (MAPU ) (មន្ត្រីចំនួន ០១ នាក់) (គ្មានសកម្មភាព)

**១០.៨-គម្រោង** (LASED) (មន្ត្រីចំនួន ០២ នាក់) (គ្មានសកម្មភាព)

**១០.៩-គម្រោងស្បៀងបន្ទាន់** (Cash for Work)(មន្ត្រីចំនួន ០៤ នាក់)

- គម្រោងក្រាលក្រួសក្រហមចំនួន ២ ខ្សែគឺ ១.ពីភូមិ និមិត្ត ដល់ ភូមិផ្លុង ឃុំទីពោ ស្រុកសន្ទុក ប្រវែង ៤,៣៧៧ គ.ម អនុវត្តបាន៨០%។ ២.ផ្លូវ ភូមិ រលាក់ពេន ឃុំ ទ្រៀល ស្រុក បារាយណ៍ ប្រវែង ២,៧ គ ម អនុវត្តបាន ១០០%
- គម្រោងសាច់ប្រាក់ពលកម្ម ការងារជីស នៅភូមិខ្សាច់ជីរស់ ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ចំនួន ១ ខ្សែ ប្រវែង ១,៥១ គ.ម សម្រេចបាន ១០០%

**១០.១០-គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ** (មន្ត្រីចំនួន ០៣ នាក់)

- បានចុះរៀបចំឥណទានក្រុមថ្មីមានចំនួន ៥ នាក់បន្ថែមទៀត
- បានចុះប្រមូលលុយគ្រប់ចំនួនពីអតិថិជនចាស់ ក្នុងនោះមានម្នាក់បង់ផ្តាច់
- បានផ្តល់ឥណទានទៅក្រុមថ្មីមានគ្នា ៥ នាក់ (ដោយយកលុយពីការប្រមូលប្រាក់ដើម និងការប្រាក់ពីអតិថិជនចាស់) ដូចនេះ អតិថិជនរបស់គម្រោងនេះ មានអតិថិជនសរុបចំនួន ២៩ នាក់
- បានចុះតាមដានអតិថិជនដែលខ្ចីលុយយកទៅប្រកបមុខរបរ និងបានផ្សព្វផ្សាយពីគោលការណ៍គម្រោងឥណទានដល់អតិថិជនដែលមានបំណងចង់ខ្ចីឥណទាន

## III. **ទិសដៅបន្ត**

នឹងសាងសង់ផ្លូវជនបទក្រាលកៅស៊ូ DBST ជំហានទី២ប្រមាណជា ១២២,៧ គ.ម ក្នុងនោះគឺ ៖

- ០ផ្លូវពីទ្រា ដល់សាគ្រាម ប្រវែង ៤៩ គ.ម ស្រុក ស្ទោង និង ប្រាសាទបល្ល័ង្គ
- ០ផ្លូវពីតារាម ដល់ ស្ទោញ ប្រវែង ២០ គ.ម ស្រុកប្រាសាទបល្ល័ង្គ និងស្រុក កំពង់ស្វាយ
- ០ផ្លូវពីកំពង់ស្បូវ ដល់ ងន ប្រវែង ២០,៤ គ.ម ស្រុកប្រាសាទសំបូរ និងស្រុកសណ្តាន់
- ០ផ្លូវពីសាលាវិស័យ ដល់ ក្រយា ប្រវែង ៣២,២ គ.ម ស្រុកប្រាសាទបល្ល័ង្គ។

- ថែទាំផ្លូវជាលក្ខណៈខួប ផ្លូវក្រាលគ្រួសក្រហម ចំនួន ០៣ ខ្សែ ប្រវែង ១៥ គ.ម ស្ថិត ក្នុងឃុំត្រពាំងឫស្សី និងឃុំជ័យ ស្រុកកំពង់ស្វាយ និងឃុំចុងដូង ស្រុកបារាយណ៍ (គម្រោង TSLRDP)
- អង្គការ ADRA គ្រោង ២០១៥ នឹងផ្តល់បង្គន់អនាម័យចំនួន ២០០ បង្គន់ និងផ្តល់ធុងចម្រោះទឹកស្អាត ៤៦០ ធុង នៅស្រុកបារាយណ៍ និងសន្ទុក

## IV. **សំណូមពរ**

- រិះរកមធ្យោបាយណាដើម្បីឲ្យសហគមន៍ចូលរួមសាងសង់ និងទិញបង្គន់អនាម័យយកទៅប្រើប្រាស់
- ស្នើសុំថវិកាទៅតាមផែនការសម្រាប់ឆ្នាំ ២០១៥ ឲ្យបានទាន់ពេលវេលា។
- គួរមានប្រាក់ឧបត្ថម្ភដល់សមាជិក គ.អ.ភ
- ពង្រឹងការអនុវត្តតួនាទី ភារកិច្ចការិយាល័យជំនាញ និង ក្រុង ស្រុក
- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ ក្នុងការបំពេញការងារប្រចាំថ្ងៃ
- ឲ្យមានការបណ្តុះបណ្តាលមន្ត្រីបន្ថែមទាំងរយៈពេលខ្លី វែង
- ស្នើសុំឥណទានបន្ថែមសម្រាប់គម្រោងឥណទាន ក.អ.ជ ពីព្រោះអតិថិជនត្រូវការខ្ចីច្រើន

ប្រធានមន្ទីរ